ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០០៧......សហវ.សរ.សម

# សារាចរណែនាំ
# ស្តីពី
# ការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្តឆ្នាំ ២០២៥-២០២៧ និងនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០២៥

## ១. សេចក្តីផ្តើម

អនុលោមតាមមាត្រា ៥១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងសារាចរស្តីពីប្រតិទិនសម្រាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥, រាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខ័ណ្ឌថវិការយៈពេលមធ្យម, សារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៥-២០២៧ និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥។ ផ្អែកលើក្របខ័ណ្ឌ និងសារាចររាជរដ្ឋាភិបាលខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវដាក់ចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្តឆ្នាំ ២០២៥-២០២៧ និងនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០២៥។

សារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្តឆ្នាំ ២០២៥-២០២៧ និងនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០២៥ នឹងផ្តល់នូវគោលការណ៍ និងបច្ចេកទេសគន្លឹះថ្មីៗ សម្រាប់ធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ និងកំណត់នូវក្របខ័ណ្ឌ និងវិធានដើម្បីការបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូលអាទិភាពចំណាយ ព្រមទាំងកំណត់នូវគោលការណ៍សំខាន់ៗសម្រាប់បង្កើនប្រសិទ្ធភាពនៃការរៀបចំគម្រោងថវិកា ហើយការវិភាជថវិកាត្រូវផ្អែកលើលទ្ធភាពជាក់ស្តែងនៃទំហំថវិកា និងអាទិភាពគោលនយោបាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកលើក្របខ័ណ្ឌថវិការយៈពេលមធ្យមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ២. ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧

ឯកសារក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧ បានកំណត់នូវក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ដូចខាងក្រោម÷


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

## ២.១. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

សម្រាប់ឆ្នាំ ២០២៥, សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថា នឹងសម្រេចបានកំណើនក្នុងរង្វង់ ៦,៣% និងជាមធ្យម ៦,៦% សម្រាប់ឆ្នាំ ២០២៦-២០២៧, ដែលក្នុងនោះ÷ (១). វិស័យឧស្សាហកម្ម ត្រូវបានព្យាករថាមានកំណើនល្អប្រសើរក្នុងអត្រា ៨,៦% ក្នុងឆ្នាំ ២០២៥ និងក្នុងរង្វង់អត្រា ៩,០% សម្រាប់រយៈពេលមធ្យម (២០២៦-២០២៧)។ (២). វិស័យសេវាកម្ម ត្រូវបានព្យាករថានឹងមានកំណើនក្នុងអត្រាប្រមាណ ៥,៦% ក្នុងឆ្នាំ ២០២៥ និងប្រមាណ ៥,៧% សម្រាប់រយៈពេលមធ្យម (២០២៦-២០២៧)។ (៣). វិស័យកសិកម្ម ត្រូវបានព្យាករថានឹងមានកំណើន ១,១% ក្នុងឆ្នាំ ២០២៥ និង ១,៣% សម្រាប់ឆ្នាំ ២០២៦-២០២៧ ដោយសារការរំពឹងទុកនូវកំណើនល្អប្រសើរនៃអនុវិស័យដំណាំនិងចិញ្ចឹមសត្វ និងការងើបសន្សឹមៗនៃអនុវិស័យនេសាទ។

យ៉ាងណាមិញ, សម្រាប់រយៈពេលមធ្យមខាងមុខ ពិសេសសម្រាប់ឆ្នាំ ២០២៥, សេដ្ឋកិច្ចកម្ពុជាក៏នឹងនៅបន្តជួបប្រទះនឹងហានិភ័យ និងបញ្ហាប្រឈមចម្បងៗ ជាពិសេស ពីកត្តាខាងក្រៅ ដែលអាចធ្វើឱ្យកំណើនដែលបានព្យាករខាងលើនេះ មិនអាចសម្រេចបានតាមការគ្រោងទុក ក៏ដូចជាអាចទាញពន្យឺតដល់កំណើនសេដ្ឋកិច្ចជារួម ក្នុងរយៈពេលមធ្យមខាងមុខ។

ការលេចឡើងនូវនិន្នាការថ្មីៗ តម្រូវឱ្យកម្ពុជាខិតខំពង្រីក និងបន្តពង្រឹងមូលដ្ឋានខាងក្នុង ឱ្យកាន់តែមានភាពប្រកួតប្រជែង ដើម្បីស្រូប និងទាញយកប្រយោជន៍ពីកាលានុវត្តភាពថ្មីៗទាំងនោះ ក៏ដូចជាបន្តកសាងភាពធន់នៃសង្គម-សេដ្ឋកិច្ច ដោយផ្តោតលើការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១ ដើម្បីអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបញ្ចៀសហានិភ័យ ដែលនឹងកើតឡើងក្នុងពេលខាងមុខជាយថាហេតុ។

ក្នុងរយៈពេលមធ្យមខាងមុខ (ឆ្នាំ ២០២៥-២០២៧), អត្រាអតិផរណា ត្រូវបានព្យាករថានឹងស្ថិតក្នុងរង្វង់ ២,៥% ដោយសារការរក្សាបាននូវចលនការសេដ្ឋកិច្ចក្នុងស្រុក និងប្រក្រតីភាពនៃស្ថានភាព និងថ្លៃទំនិញអន្តរជាតិ ចំណែកអត្រាប្តូរប្រាក់ផ្លូវការ ត្រូវបានរំពឹងថានឹងរក្សាបានក្នុងរង្វង់ជាមធ្យម ៤ ០៦០រៀលក្នុងមួយដុល្លារអាម៉េរិក។

## ២.២. ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

ផ្អែកលើមូលដ្ឋានក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចខាងលើ និងការវិវត្តជាក់ស្តែងនៃស្ថានភាពហិរញ្ញវត្ថុសាធារណៈ ព្រមទាំងក្នុងបរិការណ៍នៃភាពមិនប្រាកដប្រជាកាន់តែខ្ពស់, គោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់រយៈពេលមធ្យមខាងមុខ ត្រូវបានរៀបចំឡើងដោយប្រកាន់យកនូវជំហាននៃការបន្តអនុវត្ត **«ជំហរគោលនយោបាយពង្រឹងប្រសិទ្ធភាពថវិកា»** ដើម្បីធានាឱ្យបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលមធ្យម តាមរយៈការចាប់ផ្តើមកសាងទ្រនាប់ថវិកាឡើងវិញ បន្ទាប់ពីបានអនុវត្តគោលនយោបាយវិត្ថារកម្មចំណាយក្នុងការអនុវត្តវិធានការអន្តរាគមន៍សង្គម-សេដ្ឋកិច្ចឆ្នាំ ២០២០-២០២៣ ទប់ទល់នឹងផលប៉ះពាល់ធ្ងន់ធ្ងរពីវិបត្តិជំងឺកូវីដ-១៩។

ក្នុងន័យនេះ, រាជរដ្ឋាភិបាលនឹងផ្តោតជាសំខាន់លើការបន្តពង្រឹងប្រសិទ្ធភាពថវិកា, ទាំងកម្រិតវិភាជន៍ និងកម្រិតប្រតិបត្តិការតាមរយៈការបន្តធ្វើអាទិភាវូបនីយកម្មចំណាយ ដោយតម្រង់ទិសធនធានទៅកាន់មុខ

សញ្ញាចំណាយដែលជាអាទិភាពចំពោះមុខគី ចាយវាយឱ្យចំទិសដៅ និងធានាបានតម្លៃនៃលុយ ព្រមជាមួយនឹងការខិតខំពង្រឹងការប្រមូលចំណូលឱ្យបានកាន់តែប្រសើរ ដោយមានការថ្លឹងថ្លែងជាមួយនឹងការបន្តរក្សាឱ្យបាននូវចលនការ និងសន្ទុះនៃសកម្មភាពសេដ្ឋកិច្ច។ ក្នុងស្មារតីនេះ, រាជរដ្ឋាភិបាលនឹងដាក់ចេញនូវវិធានការពន្ធដែលមានការកែទម្រង់ស៊ីជម្រៅទៅលើផ្នែករដ្ឋបាល និងទំនើបភាវូបនីយកម្មពន្ធ ក្រោមអភិក្រមមិនបង្កើតបន្ទុកពន្ធថ្មីដោយថ្លឹងថ្លែងការរក្សាបាននូវចលនការសេដ្ឋកិច្ច និងការបន្តបង្កើនចំណូលសម្រាប់តម្រូវការអភិវឌ្ឍន៍ជាតិ។ រីឯផ្នែកចំណាយ នឹងត្រូវពង្រឹងប្រសិទ្ធភាពប្រកបដោយស្មារតីប្រុងប្រយ័ត្នខ្ពស់ ដើម្បីធានាឱ្យបាននូវលទ្ធភាពក្នុងការទ្រទ្រង់ចលនការអភិវឌ្ឍន៍សេដ្ឋកិច្ច។

### ២.២.១ ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧

ផ្អែកតាមក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧ ព្រមជាមួយនឹងគោលនយោបាយផ្នែកម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលបានកំណត់ខាងលើ, ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧ បានកំណត់ពិតានចំណាយគោល ផ្នែកចំណាយបន្ទុកបុគ្គលិក និងមិនមែនបន្ទុកបុគ្គលិកជូនដល់គ្រប់រដ្ឋបាលរាជធានី ខេត្ត និងពិតានគោលសរុបរួមជូនរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់។ ការកំណត់ពិតានចំណាយគោលដល់កម្រិតរដ្ឋបាលរាជធានី ខេត្ត ធ្វើឡើងដើម្បីពង្រឹងគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា, ការបន្តពង្រឹងវិន័យថវិកា និងការបង្កើនប្រសិទ្ធភាពចំណាយ។ ដូចនេះ, ពិតានចំណាយគោលឆ្នាំ ២០២៥-២០២៧ នឹងផ្តល់នូវការធានាធនធានហិរញ្ញវត្ថុ និងថវិកាជូនដល់គ្រប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ដូចដែលបានរៀបចំ និងមានភ្ជាប់ជូនក្នុងតារាងនៃឧបសម្ព័ន្ធ សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៥-២០២៧ និងសម្រាប់រៀបចំគម្រោងថវិកាឆ្នាំ ២០២៥ របស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

### ២.២.២. ក្របខ័ណ្ឌថវិកាឆ្នាំ ២០២៥

ក្នុងបរិបទ និងទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច និងក្នុងទិសដៅសម្រេចឱ្យបាននូវគោលបំណងនៃក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈខាងលើ ក្របខ័ណ្ឌថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០២៥ ត្រូវកំណត់ដូចខាងក្រោម÷

- ✓ **ចំណូលសរុបថវិកាថ្នាក់ក្រោមជាតិឆ្នាំ ២០២៥** ត្រូវគ្រោងសម្រេចបានក្នុងទំហំប្រមាណ ២,០៣% នៃ ផ.ស.ស. និងប្រភពចំណូលសំខាន់ៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន÷
  - **ថវិការដ្ឋបាលរាជធានី ខេត្ត** មានប្រភពចំណូលពី ចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងចំណូលផ្សេងៗទៀត រួមមាន ចំណូលឧបត្ថម្ភធនពីថ្នាក់ជាតិ និងចំណូលផ្សេងៗដទៃទៀតដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិជាធរមាន។
  - **ថវិការដ្ឋបាលក្រុង ស្រុក** ទទួលបានការវិភាជថវិកាក្នុងកម្រិតអត្រា ១,៦% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ ២០២៤។ នៅឆ្នាំ ២០២៥ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងធ្វើការបែង

ចែកចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្ត ក្នុងអត្រា ៤% ជូនរដ្ឋបាលក្រុង ស្រុក សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន។ ជាមួយគ្នានេះផងដែរ សម្រាប់ឆ្នាំ ២០២៥ រដ្ឋបាលក្រុង ស្រុក ខណ្ឌ នឹងទទួលបានថវិកាឧបត្ថម្ភពីថ្នាក់ជាតិ សម្រាប់ចំណាយអនុវត្តមុខងារនៃការិយាល័យជំនាញទាំង១៩វិស័យរបស់មន្ទីរជំនាញរាជធានី ខេត្ត ដែលបានធ្វើសមាហរណកម្មចូលទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

- **ថវិការដ្ឋបាលឃុំ សង្កាត់** ទទួលបានការវិភាជថវិកាក្នុងកម្រិតអត្រា ៣,៥% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ ២០២៤។ នៅឆ្នាំ ២០២៥ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងធ្វើការបែងចែកចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្ត ក្នុងអត្រា ៦% ជូនរដ្ឋបាលឃុំ សង្កាត់ (លើកលែងសង្កាត់ចំណុះរាជធានីភ្នំពេញ) សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន។ ជាមួយគ្នានេះផងដែរ, រាជរដ្ឋាភិបាលនឹងធ្វើការផ្ទេរធនធានថវិកាបន្ថែមលើមូលនិធិឃុំ សង្កាត់ (លើកលែងសង្កាត់ចំណុះរាជធានីភ្នំពេញ) សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ស្មើនឹងអត្រា ១% នៃចំណូលចរន្តថវិកាថ្នាក់ជាតិដែលបានអនុម័តឆ្នាំ ២០២៤។
- នៅឆ្នាំ ២០២៥, រាជរដ្ឋាភិបាល បន្តអនុវត្តការធ្វើវិមជ្ឈការមុខងារអប់រំ នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេស ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រង និងការផ្តល់សេវាអប់រំ ប្រកបដោយប្រសិទ្ធភាព តាមរយៈការបង្កើតការទទួលខុសត្រូវ ក្នុងការគ្រប់គ្រង និងការផ្តល់សេវាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

✓ **ចំណាយសរុបថវិកាថ្នាក់ក្រោមជាតិឆ្នាំ ២០២៥** ត្រូវបានគ្រោងក្នុងរង្វង់ ២,០៣% នៃ ផ.ស.ស. ដែលក្នុងនោះ ថវិកាផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិសរុបមានប្រមាណ ១,១៩% នៃ ផ.ស.ស. និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់រដ្ឋបាលថ្នាក់ក្រោមជាតិមានប្រមាណ ០,៨៤% នៃ ផ.ស.ស.។ ចំណាយចរន្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០២៥ ត្រូវកំណត់ត្រឹម ១,៧៩% នៃ ផ.ស.ស. ក្នុងនោះចំណាយបន្ទុកបុគ្គលិក ០,៤៦% នៃ ផ.ស.ស. និងចំណាយមិនមែនបន្ទុកបុគ្គលិក ១,៣៣% នៃ ផ.ស.ស.។ សម្រាប់ឆ្នាំ ២០២៦-២០២៧, ចំណាយសរុបថ្នាក់ក្រោមជាតិ នឹងគ្រោងឱ្យមានកំណើនក្នុងអត្រាជាមធ្យមប្រមាណ ៨,០% ក្នុងមួយឆ្នាំ ដែលនឹងស្ថិតក្នុងរង្វង់ ១,៩៧% នៃ ផ.ស.ស. ត្រឹមឆ្នាំ ២០២៧ ដើម្បីគាំទ្រដល់ការអភិវឌ្ឍ និងការលើកកម្ពស់គុណភាពនៃសេវាសាធារណៈនៅមូលដ្ឋាន តាមរយៈការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី ២ ឆ្នាំ ២០២១-២០៣០។

## ៣. គោលការណ៍ និងបច្ចេកទេសនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ឆ្នាំ ២០២៥-២០២៧

ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលបានគូសរំលេចខាងលើ រួមជាមួយនឹងពិតានចំណាយគោលតាមរដ្ឋបាលរាជធានី ខេត្ត និងខណ្ឌនីមួយៗ បានផ្តល់នូវមូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រឱ្យបានត្រឹមត្រូវ និងមានភាពជាក់ស្តែង។

ផែនការយុទ្ធសាស្ត្រថវិកា គឺជាឧបករណ៍ដ៏សំខាន់សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងជាយន្តការក្នុងការជួយបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការប្រើប្រាស់ថវិកា តាមរយៈការជួយតម្រង់ និងជំរុញការវិភាជថវិកាឱ្យចំទិសដៅ ការវិភាជថវិកាបម្រើឱ្យសកម្មភាពអាទិភាព និងការវិភាជថវិកាមានភាពជាក់ស្តែង ដើម្បីឆ្លុះបញ្ចាំងអំពីសមិទ្ធផលសម្រេចបានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងឆ្ពោះទៅការសម្រេចឱ្យបាននូវគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល។

ស្របតាមទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥ ផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត នឹងក្លាយជាផែនការយុទ្ធសាស្ត្ររួម តាមរយៈការធ្វើសមាហរណកម្មផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការតម្រឹមជាមួយនឹងអាទិភាពតាមវិស័យនៃក្រសួង ស្ថាប័នថ្នាក់ជាតិ (មន្ទីរជំនាញរាជធានី ខេត្ត)។ ដំណើរការនេះ គឺជានាំឱ្យមានការផ្សារភ្ជាប់គ្នាប្រកបដោយប្រសិទ្ធភាពរវាងផែនការ/កម្មវិធីនៃថវិកាថ្នាក់ក្រោមជាតិទៅនឹងអាទិភាពជាតិ ដើម្បីប្រើប្រាស់ធនធានដែលមានកម្រិតក្នុងការសម្រេចឱ្យបានសមិទ្ធផលជាអតិបរមា។ ផែនការអាទិភាពរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ នឹងត្រូវដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ទៅតាមអាទិភាពនៅថ្នាក់មូលដ្ឋាន ដែលជាតម្រូវការ និងសំណូមពររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ តាមអភិក្រមពីក្រោមឡើងលើ។

ដើម្បីអាចរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត បានគ្រប់ជ្រុងជ្រោយ គឺតម្រូវឱ្យមានការកែលម្អដំណើរការប្រឹក្សាយោបល់ និងការសម្របសម្រួលរវាងក្រសួង ស្ថាប័ន (មន្ទីរជំនាញរាជធានី ខេត្ត) រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធ តាមរយៈយន្តការសម្របសម្រួល និងពិគ្រោះយោបល់របស់ *«គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស»* ដែលដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។ ជាមួយគ្នានេះ ការបង្កើតឱ្យមានយន្តការគាំទ្រពីថ្នាក់ជាតិ ជាពិសេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺមានភាពចាំបាច់ណាស់។ តាមរយៈនេះ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំក្រុមការងារបច្ចេកទេសកម្រិតថ្នាក់ជាតិមួយ ហៅថា *«មន្ត្រីបច្ចេកទេសថវិកា»* ដើម្បីជួយដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការពិនិត្យឡើងវិញ និងកែលម្អរចនាសម្ព័ន្ធកម្មវិធី និងសូចនាករសមិទ្ធកម្ម ក្នុងគោលបំណងដើម្បីបង្កើនគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ក៏ដូចជាប្រសិទ្ធភាពក្នុងការរៀបចំថវិកាប្រចាំឆ្នាំ។

ទន្ទឹមនឹងនេះ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក៏ត្រូវបង្កើត *«ក្រុមការងារថវិកា»* ដែលមានសមាសភាពអភិបាលនៃគណៈអភិបាលរាជធានី ខេត្តជាប្រធាន អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ទទួលបន្ទុកហិរញ្ញវត្ថុ និងប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្តជាអនុប្រធាន និងមានការចូលរួមពីប្រធានរតនាគាររាជធានី ខេត្ត នាយករដ្ឋបាល នាយកទីចាត់ការហិរញ្ញវត្ថុ/ប្រធានការិយាល័យផែនការនិងហិរញ្ញវត្ថុ នាយកទីចាត់ការផែនការនិងវិនិយោគ/ប្រធានការិយាល័យផែនការនិងវិនិយោគ និងប្រធានសាខាពន្ធដារខេត្ត ខណ្ឌ ជាសមាជិក។ ក្រុមការងារថវិកា ត្រូវធ្វើការគ្រោងធនធាននិងផែនការសកម្មភាពទៅតាមរចនាសម្ព័ន្ធនៃកម្មវិធីនីមួយៗ និងផ្តោតទៅលើការកំណត់នូវសូចនាករសមិទ្ធកម្មគន្លឹះ ដោយត្រូវធ្វើយ៉ាងណាឱ្យការវិភាជថវិកាមានប្រសិទ្ធភាព និងឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រុមការងារនេះ ត្រូវរៀបចំយន្តការការងារឱ្យបានច្បាស់លាស់ និងធ្វើការ

សហការជាមួយមន្ទីរជំនាញរាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធ ដើម្បីធានាបាននូវនិរន្តរភាព និងប្រសិទ្ធភាពការងារតាមការចាំបាច់។ ទន្ទឹមនឹងនេះ, អភិបាលក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ត្រូវចូលរួមសហការអនុវត្ត ដើម្បីឱ្យការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ទទួលបានជោគជ័យ។

ជារួម រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រើប្រាស់សៀវភៅ *«គោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត»* ដែលត្រូវបានរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន។

## ៣.១. ការរៀបចំរចនាសម្ព័ន្ធផែនការយុទ្ធសាស្ត្រថវិកា

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបង្កើតរចនាសម្ព័ន្ធកម្មវិធី ដោយត្រូវឆ្លុះបញ្ចាំងអំពីការផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងគោលបំណងគោលនយោបាយ និងត្រូវមានអ្នកទទួលខុសត្រូវច្បាស់លាស់ដើម្បីធានាការផ្សារភ្ជាប់រវាងផែនការ/កម្មវិធីទៅនឹងថវិកា។ *គោលបំណងគោលនយោបាយ* ដែលបានបង្កើតសម្រាប់ចក្ខុវិស័យរយៈពេលមធ្យម និងវែង (៣-៥ឆ្នាំ) ត្រូវផ្អែកលើគោលនយោបាយតាមវិស័យដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, ផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវមានគោលដៅបម្រើឱ្យវិស័យអាទិភាពទាំងបួន(៤) គឺ÷ វិស័យសេដ្ឋកិច្ច, វិស័យសង្គមកិច្ច, វិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ និងវិស័យរដ្ឋបាលទូទៅ។

ដើម្បីផ្តល់ភាពងាយស្រួលក្នុងការរៀបចំរចនាសម្ព័ន្ធកម្មវិធី គ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់គួរមានគោលបំណងគោលនយោបាយតែមួយ (១) គត់ គឺ *«ដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍរដ្ឋបាលសាធារណៈ និងសេវាសាធារណៈរាជធានី ខេត្ត»*។

ផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ត្រូវបានកំណត់ឱ្យមានកម្មវិធីយ៉ាងច្រើនបំផុតត្រឹម ០៤ កម្មវិធី ដើម្បីផ្តល់ភាពងាយស្រួលក្នុងការតម្រឹមផែនការ/កម្មវិធីនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងអាទិភាពតាមវិស័យនៃក្រសួង ស្ថាប័នថ្នាក់ជាតិសម្រាប់ថវិកាមន្ទីរជំនាញរាជធានី ខេត្ត។ ដោយឡែក, សម្រាប់ចំនួនអនុកម្មវិធី និងចង្កោមសកម្មភាពពុំមានកំណត់ចំនួនឡើយ។ ក្រុមការងារថវិកា ត្រូវរៀបចំឯកសារផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ផ្អែកតាមឧបសម្ព័ន្ធទី១ (រចនាសម្ព័ន្ធនៃផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត) នៃ *គោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ដែលត្រូវបានដាក់ឱ្យអនុវត្តដោយប្រកាសលេខ ៤៥៧ សហវ.ប្រក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*។

## ៣.២. ការពង្រឹងការកំណត់សូចនាករសមិទ្ធកម្ម និងគោលដៅនៃសូចនាករសមិទ្ធកម្ម

ក្នុងជំហានឆ្ពោះទៅការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្មនៅក្រោយឆ្នាំ២០២៥ រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ ដែលអនុវត្តថវិកាកម្មវិធី ត្រូវមានការយកចិត្តទុកដាក់ខ្ពស់ និងពង្រឹងគុណភាពនៃការកំណត់សូចនាករ។

ការកំណត់សូចនាករសមិទ្ធកម្មគន្លឹះ និងគោលដៅសូចនាករសមិទ្ធកម្មឱ្យបានច្បាស់លាស់ គឺជាយន្តការដ៏សំខាន់ សម្រាប់ធ្វើការតាមដានវឌ្ឍនភាព និងសមិទ្ធផល និងជាមធ្យោបាយសម្រាប់បង្ហាញភស្តុតាងដែលកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព សម្រេចបាននូវលទ្ធផលតាមការរំពឹងទុក។ រដ្ឋបាលរាជធានី

ខេត្ត និងរដ្ឋបាលខណ្ឌ អាចជ្រើសរើសសូចនាករគន្លឹះមិនឱ្យលើសពី៥ ដើម្បីងាយស្រួល ក្នុងការផ្តល់ព័ត៌មានសំខាន់អំពីសមិទ្ធកម្ម ដែលជួយអ្នកពាក់ព័ន្ធយល់ដឹងច្បាស់អំពីស្ថានភាពរបស់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌសាមី ក្នុងដំណើរឆ្ពោះទៅការសម្រេចលទ្ធផលរំពឹងទុក។ សូចនាករគន្លឹះមានចំនួនតិច នឹងផ្តល់ភាពងាយស្រួលក្នុងការគ្រប់គ្រង, ផ្តល់ភស្តុតាងជាក់លាក់ និងអាចជួយអ្នកគ្រប់គ្រងងាយស្រួលក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងកែលម្អសមិទ្ធកម្ម។

ក្នុងការកំណត់សូចនាករលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយ ក្រុមការងារថវិកា ត្រូវផ្អែកលើគោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត។

### ៣.៣. ការកំណត់ធនធានថវិកា

ការគ្រោងចំណូលថវិការដ្ឋបាលរាជធានី ខេត្ត និងខណ្ឌ សម្រាប់រយៈពេលមធ្យម (២០២៥-២០២៧) ត្រូវផ្អែកលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈខាងលើ ព្រមទាំងលទ្ធផល និងបទពិសោធន៍ក្នុងការអនុវត្តនៃបណ្តាឆ្នាំកន្លងមក រួមទាំងគោលនយោបាយ និងវិធានការថ្មីដែលគ្រោងនឹងដាក់ឱ្យអនុវត្ត។ ការគ្រោងចំណូលនេះ ត្រូវគិតបញ្ចូលប្រភពចំណូលដែលស្ថិតក្រោមការគ្រប់គ្រង និងប្រមូលផ្ទាល់ ចំណូលដែលបានពីថវិកាជាតិ និង ចំណូលពីប្រភពផ្សេងៗ ស្របតាមបទដ្ឋានគតិយុត្តជាធរមាន។ រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ ដែលមានប្រភពចំណូល គឺត្រូវរៀបចំដាក់ចេញវិធានការសម្រាប់ពង្រឹងការគ្រប់គ្រង និងប្រមូលចំណូល។

ការគ្រោងតម្រូវការចំណាយ គឺជាការគណនាចំណាយសម្រាប់រយៈពេលមធ្យម (២០២៥-២០២៧) ទៅតាមកម្មវិធីនីមួយៗ និងទៅតាមប្រភេទចំណាយ និងប្រភពធនធានថវិកា។

ការកំណត់ពីតម្រូវការធនធាន ត្រូវផ្តោតជាសំខាន់លើកត្តាមួយចំនួនដូចខាងក្រោម៖

- ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលរួមមានកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ អត្រាអតិផរណាប្រចាំឆ្នាំ និងទិសដៅសំខាន់ៗក្នុងការកំណត់អាទិភាពនៃចំណាយ
- ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ការវាយតម្លៃការអនុវត្តចំណាយក្នុងរយៈពេលកន្លងមកនិងការប៉ាន់ស្មានការអនុវត្តចំណាយក្នុងឆ្នាំកំពុងអនុវត្តរបស់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ
- ការកំណត់តម្រូវការធនធានទៅតាមឆ្នាំនីមួយៗត្រូវមានភាពជាក់ស្តែង ដើម្បីឆ្លើយតបទៅតាមតម្រូវការរបស់កម្មវិធីនីមួយៗ។

## ៤. គោលការណ៍ និងបច្ចេកទេសនៃការរៀបចំគម្រោងថវិកាឆ្នាំ ២០២៥

ផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដូចបានកំណត់ខាងលើ រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់នីមួយៗ ត្រូវគ្រោងចំណូល-ចំណាយ ដូចខាងក្រោម៖

## ៤.១. ការគ្រោងចំណូលថវិកាឆ្នាំ ២០២៥

*រដ្ឋបាលរាជធានី ខេត្ត* ត្រូវរៀបចំគម្រោងចំណូល និងត្រូវខិតខំពង្រឹង និងជំរុញការប្រមូលចំណូលឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ដោយផ្អែកលើមូលដ្ឋានប្រភពចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ ដែលបានកំណត់ដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ចំណូលសារពើពន្ធត្រូវបានគ្រោងដោយផ្អែកលើ ÷

- លទ្ធផលដែលសម្រេចបាននៅក្នុងឆ្នាំកន្លងមក
- លទ្ធផលដែលទទួលបាន និងការប៉ាន់ស្មានលទ្ធផលសរុបដែលអាចសម្រេចបានក្នុងឆ្នាំកំពុងអនុវត្ត (២០២៤)
- ប៉ាន់ស្មានលើការវិវត្តអាជីវកម្មដ្ឋាននៅពេលខាងមុខ
- ការប្រែប្រួលដែលអាចកើតមានឡើងដោយអត្រា និងចំនួនមូលដ្ឋានប្រមូលពន្ធ
- ការពង្រឹង និងកែលម្អរដ្ឋបាលពន្ធដារ ។

ចំណូលមិនមែនសារពើពន្ធ ត្រូវបានគ្រោងដោយផ្អែកលើ ÷

- កិច្ចការទាំងឡាយដែលនាំឱ្យមានផលទុនចំណូលដូចជា កិច្ចសន្យាជួល សៀវភៅបន្ទុក
- សេវាកម្ម និងការកែលម្អការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- ស្ថិតិមុខសញ្ញាប្រមូលក្នុងឆ្នាំកំពុងអនុវត្ត និងការវិវត្តសេដ្ឋកិច្ចដែលនាំមកនូវមុខសញ្ញាចំណូលថ្មី
- ស្ថិតិបំណុលដែលពុំទាន់បានដោះស្រាយ
- ចំណូលដែលបានប្រតិភូកម្ម និងផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចខាងក្រោម÷
  - ✓ ចំណូលពីការបែងចែកចំណូលស្ទួយសាលើតម្លៃផលិតផលរ៉ែ ដែលអនុវត្តតាមខ្លឹមសារប្រកាសលេខ ៧៦០ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០២០ « *ស្តីពីស្ទួយសារ៉ែ* »
  - ✓ ចំណូលកម្រៃសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងចំណូលកម្រៃ សេវា និងចំណូលពីការពិន័យជាប្រាក់ដែលប្រមូលនៅមន្ទីរអង្គភាពជំនាញរាជធានី ខេត្ត ដែលអនុវត្តតាមខ្លឹមសារអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ ២០២០ ស្តីពី « *ការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត* » សារាចរ-លេខ ០០៦ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ ២០២០ « *ស្តីពីនីតិវិធី និងកិច្ចបញ្ជិកានៃការអនុវត្តចំណូលពីកម្រៃសេវា របស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងចំណូលកម្រៃសេវា និងចំណូលពីការពិន័យជាប្រាក់ដែលប្រមូលនៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត* » ប្រកាសអន្តរក្រសួងលេខ ១៤៣៤២ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០១៦ ស្តីពី « *ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ* » និងប្រកាសអន្តរក្រសួងលេខ ១៤៣៤៣ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០១៦ ស្តីពី « *ការផ្តល់ថវិកាវង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ* » ប្រកាសរួម ឬប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នសាមី

ស្តីពីការបែងចែកចំណូលពីកម្រៃសេវា និងការគ្រប់គ្រង និងបែងចែកប្រាក់រង្វាន់ និងសារាចរ-ណែនាំលេខ ០១០ សហវ.អបហក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ ២០១៤ ស្តីពី «*គោលការណ៍ និងនីតិវិធីផ្តល់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*» រួម និងលិខិតបទដ្ឋានពាក់ព័ន្ធដទៃទៀតដែលមាន។

គម្រោងចំណូលសរុបរបស់រដ្ឋបាលរាជធានី ត្រូវរួមបញ្ចូលទាំងគម្រោងចំណូលរបស់រដ្ឋបាលខណ្ឌ។

ផ្អែកលើមូលដ្ឋានកញ្ចប់គម្រោងចំណូលថវិកាប្រចាំឆ្នាំដែលបានកំណត់រួច អភិបាលនៃគណៈអភិបាលរាជធានីត្រូវធ្វើការបែងចែក និងជូនដំណឹងអំពីកញ្ចប់ថវិការបស់រដ្ឋបាលខណ្ឌនីមួយៗ ដើម្បីរៀបចំគម្រោងថវិកាលម្អិតរបស់ខ្លួន។

**ការបែងចែកកញ្ចប់ថវិកាសម្រាប់ខណ្ឌនីមួយៗត្រូវផ្អែកលើ ÷**

- កញ្ចប់ថវិការបស់រដ្ឋបាលខណ្ឌនីមួយៗដែលបានប្រើប្រាស់ក្នុងឆ្នាំកន្លងមក
- ចំណូលដែលប្រមូលបានដោយរដ្ឋបាលខណ្ឌសាមី
- តម្រូវការចាំបាច់មួយចំនួនរបស់រដ្ឋបាលខណ្ឌនីមួយៗដែលបានកំណត់ជាធរមាន
- តម្រូវការក្នុងការអនុវត្តមុខងារ ដែលអភិបាលនៃគណៈអភិបាលរាជធានីពិនិត្យឃើញថាសមស្រប ត្រូវធ្វើប្រតិភូកម្មទៅឱ្យអភិបាល នៃគណៈអភិបាលខណ្ឌនីមួយៗ។

*រដ្ឋបាលក្រុង ស្រុក* ត្រូវរៀបចំគម្រោងចំណូលដោយផ្អែកលើតួលេខដែលបានវិភាជពីមូលនិធិក្រុង ស្រុក ស្មើនឹងអត្រា ១,៦% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ ២០២៤ ព្រមទាំងប្រភពចំណូលឧបត្ថម្ភធនពីថ្នាក់ជាតិសម្រាប់ចំណាយ អនុវត្តមុខងារនៃការិយាល័យជំនាញទាំង១៩វិស័យ របស់មន្ទីរជំនាញរាជធានី ខេត្ត ដែលបានធ្វើសមាហរណកម្មចូលទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក និងប្រភពចំណូលពីកម្រៃសេវាសាធារណៈនៅការិយាល័យច្រកចេញចូលតែមួយរបស់រដ្ឋបាលក្រុង ស្រុកសាមី។ ម្យ៉ាងវិញទៀតនៅឆ្នាំ ២០២៥ រដ្ឋបាលក្រុង ស្រុក ទទួលបានចំណូលបែងចែកពីចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្ត ចំនួន៤% ជូនរដ្ឋបាលក្រុង ស្រុក សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងជូនដំណឹងតួលេខវិភាជនៅពេលក្រោយ។

រដ្ឋបាលខណ្ឌចំណុះរាជធានី ត្រូវរៀបចំគម្រោងចំណូលដោយផ្អែកលើតួលេខប្រភពចំណូលបែងចែកពីរដ្ឋបាលរាជធានី ព្រមទាំងប្រភពចំណូលឧបត្ថម្ភធនពីថ្នាក់ជាតិ សម្រាប់ចំណាយអនុវត្តមុខងារនៃការិយាល័យជំនាញទាំង១៩វិស័យរបស់មន្ទីរជំនាញរាជធានី ខេត្ត ដែលបានធ្វើសមាហរណកម្មចូលទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ និងប្រភពចំណូលពីកម្រៃសេវាសាធារណៈនៅរដ្ឋបាលខណ្ឌនីមួយៗ។

*រដ្ឋបាលឃុំ សង្កាត់* ត្រូវរៀបចំគម្រោងចំណូលដោយផ្អែកលើតួលេខដែលបានវិភាជពីមូលនិធិឃុំ សង្កាត់ ស្មើនឹងអត្រា ៣,៥% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ ២០២៤ និងចំណូលដែលរដ្ឋបាលឃុំ សង្កាត់ប្រមូលបានពីការផ្តល់សេវារដ្ឋបាល (យន្តការច្រកចេញចូលតែមួយ) និងប្រភពចំណូលផ្សេងៗ ព្រមទាំងចំណូលថវិកាឧបត្ថម្ភបន្ថែមពីថ្នាក់ជាតិលើមូលនិធិឃុំ សង្កាត់ (លើកលែងសង្កាត់ចំណុះរាជធានីភ្នំពេញ) សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ស្មើនឹងអត្រា ១% នៃចំណូលចរន្តថវិកាថ្នាក់ជាតិដែលបានអនុម័តឆ្នាំ ២០២៤។ ចំពោះចំណូលបែងចែកពីចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្ត ចំនួន ៦% (លើកលែង

សង្កាត់ចំណុះរាជធានី) សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងជូនដំណឹងតួលេខវិភាជនៅពេលក្រោយ។

**៤.២. ការគ្រោងចំណាយថវិកាឆ្នាំ ២០២៥**

*រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ* ត្រូវរៀបចំគម្រោងថវិកាចំណាយលម្អិតទៅតាមជំពូក គណនី និងអនុគណនីស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកា និងទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព និងជាពិសេស ត្រូវយកចិត្តទុកដាក់លើការកំណត់លទ្ធផល ឬធាតុចេញ (Output) ដែលនឹងសម្រេចបាន ដើម្បីឈានទៅសម្រេចបានគោលបំណងគោលនយោបាយ ដែលបានដាក់ចេញនៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន និងដើម្បីជាមូលដ្ឋានសម្រាប់ធ្វើជាអំណះអំណាង និងគាំទ្រដល់ការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់ការចរចាថវិកាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ ត្រូវរៀបចំរចនាសម្ព័ន្ធថវិកាកម្មវិធី និងគម្រោងចំណាយថវិកាឆ្នាំ ២០២៥ ទៅតាមទម្រង់គំរូតារាងឧបសម្ព័ន្ធទី៣ ដូចបានជូនភ្ជាប់។

*រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់* ត្រូវរៀបចំគម្រោងចំណាយលម្អិតទៅតាមជំពូក គណនី និងអនុគណនី ស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកា ដោយផ្អែកលើមូលដ្ឋានចំណូលសរុបដែលបានគណនារួច។ ចំពោះចំណូលទទួលបានពីការផ្ទេរធនធានថវិកាបន្ថែមលើមូលនិធិឃុំ សង្កាត់សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន, រដ្ឋបាលឃុំ សង្កាត់ (លើកលែងសង្កាត់ចំណុះរាជធានីភ្នំពេញ) ត្រូវរៀបចំគម្រោងចំណាយសម្រាប់ អភិវឌ្ឍន៍មូលដ្ឋាន លើមុខសញ្ញាចំណាយដូចជា ការងារជួលជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធនានា ដែលបម្រើឱ្យផលប្រយោជន៍សាធារណៈ និងចំណាយមូលធន ឬអាចបញ្ចូលជាមួយធនធានសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន ដែលទទួលបានពីមូលនិធិឃុំ សង្កាត់ សម្រាប់គោលដៅចំណាយអភិវឌ្ឍន៍មូលដ្ឋានដូចខាងលើ។

***ក្នុងការរៀបចំគម្រោងចំណាយថវិកាឆ្នាំ ២០២៥ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធានាឱ្យបាននូវការគ្រោងចំណាយរបស់ខ្លួនដោយអនុលោមទៅតាមគោលការណ៍ និងបណ្តាវិធានការដូចខាងក្រោម÷***

**ក. បន្ទុកបុគ្គលិក**

ចំណាយបន្ទុកបុគ្គលិក (ជំពូក៦៤) ត្រូវបានចាត់ទុកជាចំណាយដែលមានអាទិភាពបំផុតក្នុងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ដូច្នេះចំណាយសម្រាប់បន្ទុកបុគ្គលិកថ្នាក់រដ្ឋបាលនីមួយៗត្រូវតែគិតគូរឱ្យបានច្បាស់លាស់ទៅតាមគោលការណ៍ដំឡើងបៀវត្សរបស់រាជរដ្ឋាភិបាល ព្រមទាំងធានាបាននូវសមធម៌ សង្គតិភាព និងប្រសិទ្ធភាព ជាពិសេស ធានាបាននូវស្ថេរភាព ចីរភាពថវិកា និងគម្លាតសមស្របរវាង អ្នកមានបៀវត្សខ្ពស់ និងអ្នកមានបៀវត្សទាប។ ចំណាយបន្ទុកបុគ្គលិក (ជំពូក៦៤) ត្រូវគ្រោងទៅតាមចំនួនក្របខណ្ឌមន្ត្រីរាជការ ដោយផ្អែកតាមតារាងប្រព័ន្ធប្រាក់បៀវត្សរបស់ក្រសួងមុខងារសាធារណៈ។

***គោលការណ៍សម្រាប់ការគ្រោងចំណាយបន្ទុកបុគ្គលិកសំខាន់ៗឆ្នាំ ២០២៥ មានដូចខាងក្រោម÷***

- រក្សាកម្រិតសន្ទស្សន៍បៀវត្សមូលដ្ឋានស្មើនឹងឆ្នាំ ២០២៤(ឯកតាសន្ទស្សន៍បៀវត្សមូលដ្ឋាន ២ ៦៣០រៀល ក្នុង ១ ឯកតាសន្ទស្សន៍ ឆ្នាំ ២០២៥)

- ប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល សម្រាប់ឆ្នាំ២០២៥ ត្រូវបានគ្រោងដំឡើងចំនួន ៤០ ០០០ រៀល ក្នុងម្នាក់ក្នុងមួយខែ ដើម្បីរក្សាលំនឹង និងលើកកម្ពស់ជីវភាពជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដោយគិតចាប់ពីខែមករា ដល់ខែធ្នូ ។
- សម្រាប់ឆ្នាំ២០២៥ ប្រាក់ឧបត្ថម្ភប្រចាំខែរបស់ក្រុមប្រឹក្សារដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ សមាជិកភូមិ និងប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត និងប្រធានការិយាល័យប្រជាពលរដ្ឋនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវគ្រោងកើនចាប់ពីខែមករា ដល់ខែធ្នូ ដូចខាងក្រោម÷
  - ✓ ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត និងសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវគ្រោងកើន ៣៥ ០០០ រៀល ក្នុងម្នាក់ក្នុងមួយខែ
  - ✓ ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវគ្រោងកើន ៣០ ០០០ រៀល ក្នុងម្នាក់ក្នុងមួយខែ
  - ✓ មេឃុំ ចៅសង្កាត់, ជំទប់ទី១ ទី២ ចៅសង្កាត់រងទី១ ទី២, និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវគ្រោងកើន ២៥ ០០០ រៀល ក្នុងម្នាក់ក្នុងមួយខែ
  - ✓ មេភូមិ ត្រូវគ្រោងកើន ២០ ០០០ រៀល ក្នុងម្នាក់ក្នុងមួយខែ
  - ✓ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវគ្រោងកើន ១៥ ០០០ រៀល ក្នុងម្នាក់
- ប្រាក់ឧបត្ថម្ភរបស់ប្រធាន និងអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត និងប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ ត្រូវគ្រោងកើនចាប់ពីខែមករា ដល់ខែធ្នូ ដូចខាងក្រោម÷
  - ✓ ប្រធានការិយាល័យ និងអនុប្រធានការិយាល័យប្រជាពលរដ្ឋនៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត ត្រូវគ្រោងកើន ៣៥ ០០០ រៀល ក្នុងម្នាក់ក្នុងមួយខែ
  - ✓ ប្រធានការិយាល័យប្រជាពលរដ្ឋនៅថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវគ្រោងកើនចំនួន ៣០ ០០០រៀល ក្នុងម្នាក់ក្នុងមួយខែ
- ប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់ឆ្នាំ២០២៥ របស់មន្ត្រីជាប់កិច្ចសន្យា ត្រូវគ្រោងដំឡើងពី ៧៧០ ០០០រៀល ទៅដល់ ៧៩០ ០០០រៀល ដោយគិតចាប់ពីខែមករា ដល់ខែធ្នូ។
- រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវគ្រោងក្នុងកញ្ចប់ថវិកាឆ្នាំ ២០២៥ សម្រាប់ឧបត្ថម្ភបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិចំនួន ៥០ ០០០ រៀលក្នុងម្នាក់ និងបុណ្យភ្ជុំបិណ្ឌចំនួន ៥០ ០០០ រៀលក្នុងម្នាក់។

*រដ្ឋបាលរាជធានី ខេត្ត* ត្រូវរៀបចំគ្រោងឥណទានថវិកាសម្រាប់ចំណាយប្រាក់បៀវត្សរ៍សរុប រួមមានប្រាក់បៀវត្សរ៍ មន្ទីរជំនាញរដ្ឋបាលរាជធានី ខេត្ត អគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ នៅក្នុងអនុគណនី៦៤០៣៣ (បៀវត្សរ៍) តាមសមាមាត្រនៃអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ ២០២០ ស្ដីពី «*ការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត*», ប្រកាសអន្តរក្រសួងលេខ ១៤៣៤២ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០១៦ ស្ដីពី « *ការផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាល*

*ថ្នាក់ក្រោមជាតិ*, ប្រកាសអន្តរក្រសួងលេខ ១៤៣៤៣ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០១៦ ស្តីពី « *ការផ្តល់ថវិការង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ*», និងប្រកាសរួម ឬប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នសាមីស្តីពីការបែងចែកចំណូលពីកម្រៃសេវា និងការគ្រប់គ្រងនិងបែងចែកប្រាក់រង្វាន់។

ចំណាយបន្ទុកបុគ្គលិកទាំងអស់ដែលស្ថិតនៅក្រោមឱវាទរបស់ថ្នាក់រដ្ឋបាលនីមួយៗ ត្រូវបូកសរុបនៅក្នុងតារាងទី១ និងចំនួនបុគ្គលិកអចិន្ត្រៃយ៍ប្រភេទ "ក", "ខ", "គ" ក្រុមប្រឹក្សា និងចំនួនបុគ្គលិកមិនអចិន្ត្រៃយ៍ រួមមាន បុគ្គលិកអណ្តែត មន្ត្រីជាប់កិច្ចសន្យា បុគ្គលិកការិយាល័យប្រជាពលរដ្ឋ និងមន្ត្រីភូមិ ត្រូវបូកសរុបនៅក្នុងតារាងទី១ ដែលបានភ្ជាប់ជូនមកជាមួយនេះ។ សលាកប័ត្រនេះ មានចែកជាច្រើនខ្ទង់សម្រាប់កត់ត្រានូវប្រភេទបុគ្គលិកទាំងអស់ដែលថ្នាក់រដ្ឋបាលនីមួយៗមាន។

***រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ*** ត្រូវលម្អិតចំនួនបុគ្គលិកទៅតាមរដ្ឋបាលនីមួយៗ ដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន ហើយចំនួននេះ ត្រូវតែផ្ទៀងផ្ទាត់ជាមួយនឹងចំនួនដែលមាននៅក្នុងតារាងសរុបចំណាយ *(តាមតារាងប្រព័ន្ធប្រាក់បៀវត្សនៃក្រសួងមុខងារសាធារណៈ)*។

***រដ្ឋបាលរាជធានី ខេត្ត*** ត្រូវរៀបចំតារាងបូកសរុបចំនួនបុគ្គលិកអចិន្ត្រៃយ៍ និងបុគ្គលិកមិនអចិន្ត្រៃយ៍ក្នុងតារាងទី១.១។

***រដ្ឋបាលក្រុង ស្រុក ខណ្ឌ*** ត្រូវរៀបចំតារាងបូកសរុបចំនួនបុគ្គលិកអចិន្ត្រៃយ៍ និងបុគ្គលិកមិនអចិន្ត្រៃយ៍ រួមមាន ចំនួនបុគ្គលិកបម្រើការងារនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ, ចំនួនបុគ្គលិកដែលបានប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរយៈការធ្វើសមាហរណកម្មការិយាល័យជំនាញ២០ វិស័យ និងចំនួនបុគ្គលិកអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរយៈការប្រគល់មុខងារក្នុងវិស័យអប់រំ ក្នុងតារាងទី១.២។ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំតារាង ដូចខាងក្រោម÷

- រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវរៀបចំតារាងបូកសរុបចំនួនបុគ្គលិកអចិន្ត្រៃយ៍ និងបុគ្គលិកមិនអចិន្ត្រៃយ៍ ដែលបម្រើការងារនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងតារាងទី១.២.១
- រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវរៀបចំតារាងបូកសរុបចំនួនបុគ្គលិកអចិន្ត្រៃយ៍ និងបុគ្គលិកមិនអចិន្ត្រៃយ៍ដែលបានប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបានសមាហរណកម្មបុគ្គលិកការិយាល័យជំនាញ១៩ វិស័យ ក្នុងតារាងទី១.២.២
- រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវរៀបចំតារាងបូកសរុបចំនួនបុគ្គលិកអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរយៈការប្រគល់មុខងារក្នុងវិស័យអប់រំ និងបុគ្គលិកការិយាល័យអប់រំ ក្នុងតារាងទី១.២.៣

***សម្រាប់ជំនួយការហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់*** នឹងត្រូវផ្តល់ជូនប្រាក់ឧបត្ថម្ភប្រចាំឆ្នាំ ក្នុងចំនួន ១ ០០០ ០០០ រៀល/ម្នាក់ ក្នុងមួយខែ និងត្រូវបានវិភាជរួចនៅក្នុងសមាសភាពចំណាយប្រតិបត្តិការទូទៅនៃមូលនិធិឃុំ សង្កាត់ និងត្រូវគ្រោងក្នុងអនុគណនី ៦១០៩១ (ភ្នាក់ងារជាតិជាប់កិច្ចសន្យា)។

ចំពោះជំនួយការរដ្ឋបាលឃុំ សង្កាត់បច្ចុប្បន្ន ត្រូវចាត់ទុកជាភ្នាក់ងារជាតិជាប់កិច្ចសន្យា និងត្រូវគ្រោងក្នុងអនុគណនី ៦១០៩១ (ភ្នាក់ងារជាតិជាប់កិច្ចសន្យា)។

## ខ. ចំណាយប្រតិបត្តិការ

ចំណាយក្នុងជំពូក៦០ (ការទិញ) និង៦១ (សេវាកម្ម) រួមមាន ចំណាយលើដំណើរការរដ្ឋបាល ទិញសម្ភារៈ ជួសជុលតូចតាច និងចំណាយជាគុណប្រយោជន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវគ្រោងនៅក្នុងតារាងទី២ និងតារាងទី៣។

*ឥណទានចំណាយក្នុងជំពូកនេះចែកចេញជាពីរផ្នែកដូចខាងក្រោម ÷*

ទី១- សម្រាប់បម្រើឱ្យកិច្ចប្រតិបត្តិការរដ្ឋបាលសុខុសាធ ដែលចាំបាច់ត្រូវគិតគូរឱ្យបានហ្មត់ចត់ និងត្បិតត្បៀតសន្សំសំចៃ ដោយផ្អែកលើគោលការណ៍រួមរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងចំណាយសាធារណៈ។ ក្នុងឆ្នាំ ២០២៥ ចំណាយផ្នែកនេះ គឺអនុញ្ញាតឱ្យគ្រោងក្នុងកម្រិតប្រហាក់ប្រហែលនឹងឆ្នាំ ២០២៤ តែប៉ុណ្ណោះ។ ក្នុងគោលដៅប្រើប្រាស់ថវិកាឱ្យមានប្រសិទ្ធភាពការគ្រោងចំណាយក្នុងជំពូកនេះចាំបាច់ ត្រូវផ្អែកលើបរិមាណជាតុចូល ការប៉ាន់ស្មានអនុវត្តនៅក្នុងឆ្នាំ ២០២៥ ដោយផ្អែកលើតម្លៃឯកតាជាក់ស្តែងលើទីផ្សារ ហើយជៀសវាងការទិញឧបករណ៍ សម្ភារបរិក្ខារទំនើប គ្រឿងសង្ហារឹមប្រណិត និងការទទួលភ្ញៀវអធឹកអធម។ ដោយឡែកថ្លៃឈ្នួល និងបន្ទុក (អនុគណនី៦១០៣១) គឺអនុញ្ញាតឱ្យគ្រោងតែចំណាយសម្រាប់ជួលស្នាក់ការរដ្ឋបាលតែប៉ុណ្ណោះ។

*រដ្ឋបាលរាជធានី ខេត្ត* ត្រូវយកចិត្តទុកដាក់គ្រោងចំណាយលើមុខសញ្ញាសំខាន់ៗ មានដូចជា÷

- រៀបចំផែនការសកម្មភាព និងគ្រោងចំណាយសម្រាប់ប្រតិបត្តិការរបស់អង្គភាពច្រកចេញចូលតែមួយនៅក្នុងឥណទានថវិការបស់រដ្ឋបាលរាជធានី ខេត្ត ទៅតាមចំណាត់ថ្នាក់នៃមាតិកាថវិកា។
- រៀបចំផែនការសកម្មភាព និងគ្រោងចំណាយ ព្រមទាំងមានធនធានមនុស្សគ្រប់គ្រាន់សម្រាប់ផ្តល់ការគាំទ្រដល់រដ្ឋបាលឃុំ សង្កាត់ ក្នុងការសិក្សាគម្រោងឱ្យបានទាន់ពេលវេលា និងប្រកបដោយគុណភាព ដើម្បីជំរុញឱ្យរដ្ឋបាលឃុំ សង្កាត់ អនុវត្តនីតិវិធីលទ្ធកម្មសាធារណៈចំពោះគម្រោងអភិវឌ្ឍន៍ឃុំ សង្កាត់ នៅដើមឆ្នាំថវិកា ស្របតាមខ្លឹមសារសារាចរណែនាំលេខ ០០២ សហវ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ ២០២២ ស្តីពីការពន្លឿនកិច្ចលទ្ធកម្មសំណង់របស់រដ្ឋបាលឃុំ សង្កាត់។
- រៀបចំផែនការសកម្មភាព និងគ្រោងចំណាយអនុវត្តការងារផ.អ.៣ ដែលរដ្ឋបាលរាជធានី ខេត្តធ្លាប់បានអនុវត្តពាក់ព័ន្ធនឹងការអភិវឌ្ឍសមត្ថភាព, គណនេយ្យភាពសង្គម និងប្រតិបត្តិការមួយចំនួន ដូចជា ការរៀបចំវគ្គបណ្តុះបណ្តាល ការផ្សព្វផ្សាយ កិច្ចប្រជុំ និងសកម្មភាពពាក់ព័ន្ធផ្សេងៗ ទៀត។

*រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់* ត្រូវគ្រោងលម្អិតជំពូក៦១ សេវាកម្មផ្សេងៗទៀតនៅក្នុងតារាងទី៣ ដូចជាចំណាយទទួលភ្ញៀវ បេសកកម្ម ទូរស័ព្ទ ពិធីបុណ្យផ្សេងៗ...។

ទី២- សម្រាប់ចំណាយបម្រើដល់គុណប្រយោជន៍រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអភិវឌ្ឍមូលដ្ឋាន និងផ្អែកលើផែនការយុទ្ធសាស្ត្រថវិកា ផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗចាំបាច់ត្រូវរៀបចំទៅតាមលំដាប់លំដោយអាទិភាពរបស់គម្រោងចំណាយនីមួយៗ ដូចជា ផ្លូវថ្នល់

ស្ពាន សួនច្បារ លូទឹក ប្រឡាយ។ល។ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រោងឥណទានសម្រាប់ចំណាយជាគុណប្រយោជន៍របស់រដ្ឋបាលសាមី ដោយមានបញ្ជាក់អំពីបញ្ជីប៉ាន់តម្លៃ និងទីតាំងច្បាស់លាស់ ដែលជាមូលដ្ឋានសម្រាប់ការពិភាក្សាថវិកាប្រចាំឆ្នាំ។

*ទន្ទឹមនឹងនេះ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្តល់ការយកចិត្តទុកដាក់ខ្ពស់លើការរៀបចំកម្មវិធី និងគម្រោងចំណាយសម្រាប់ការជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធដែលរដ្ឋបាលសាមីបានវិនិយោគ និងអភិវឌ្ឍកន្លងមក ដើម្បីធានាបាននូវគុណភាពល្អរឹងមាំសម្រាប់ប្រជាពលរដ្ឋមូលដ្ឋាន និងលើកកម្ពស់ប្រសិទ្ធភាពនៃចំណាយសាធារណៈ។*

*ចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ការថែទាំ និងការជួសជុលតូចតាច* ត្រូវគ្រោងទៅតាមតម្រូវការនៃសកម្មភាព ឬទៅតាមបទដ្ឋានសមស្រប។ ដូចនេះ រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ មិនត្រូវគ្រោងបំប៉ោងឥណទានដែលស្នើសុំសម្រាប់ចំណាយប្រភេទនេះទេ។ ឥណទានសម្រាប់ចំណាយរដ្ឋបាលមានលក្ខណៈអចិន្ត្រៃយ៍ដូចជា ទូរស័ព្ទ អគ្គិសនី ទឹក សម្ភារការិយាល័យ ប្រេងឥន្ធនៈ និងការទទួលភ្ញៀវត្រូវគិតគូរក្នុងកម្រិតប្រហាក់ប្រហែលនឹងឆ្នាំ២០២៤ និងត្រូវគ្រប់គ្រងយ៉ាងម៉ឺងម៉ាត់ដើម្បីសន្សំសំចៃលើចំណាយប្រភេទនេះ ជាពិសេសឥណទានសម្រាប់ចំណាយអគ្គិសនី ទឹក សម្រាប់គុណប្រយោជន៍របស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រោងឱ្យបានគ្រប់គ្រាន់សម្រាប់តម្រូវការក្នុងឆ្នាំ និងការសងបំណុល និងទូទាត់ជំរះបញ្ជីបុរេប្រទាន។ ក្នុងករណីដែលរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គ្រោងមិនបានគ្រប់គ្រាន់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងធ្វើនិយ័តភាពឥណទានផ្ទៃក្នុងជំពូកថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ហើយដាក់កម្មវិធីចំណាយសម្រាប់ទូទាត់ជូនរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដោយស្វ័យប្រវត្តិ។ ចំពោះគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុក ដែលរៀបចំមិនត្រឹមត្រូវតាមគោលការណ៍ណែនាំខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងធ្វើការកែតម្រូវថវិការបស់រដ្ឋបាលក្រុង ស្រុក ឡើងវិញឱ្យសមស្របតាមសារាចរណែនាំនេះ។

**គ. ចំណាយមូលធន**

ចំណាយមូលធនសម្រាប់គម្រោងវិនិយោគនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបន្តអនុវត្តតាមនីតិវិធីដែលបាន និងកំពុងអនុវត្តជាធរមាន និងស្របតាមគោលការណ៍ណែនាំស្តីពី *«នីតិវិធីប្រតិបត្តិការនៃការរៀបចំ និងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ»* ដែលដាក់អនុវត្តដោយប្រកាសលេខ ០០៣ សហវ.ប្រក.អហក ចុះថ្ងៃទី៩ ខែមករា ឆ្នាំ ២០២៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចខាងក្រោម÷

- ✓ ការកំណត់អត្តសញ្ញាណគម្រោង ដើម្បីរៀបចំបញ្ជីគម្រោងវិនិយោគបឋម ត្រូវមានការចូលរួមពីប្រជាពលរដ្ឋនៅមូលដ្ឋាន និងជ្រើសរើសគម្រោងដែលអាចបម្រើប្រយោជន៍ប្រជាពលរដ្ឋនៅមូលដ្ឋាន។ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងលេខ ០១៤៩ ជកប្រ.ក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ ២០២០ ស្តីពី *«ការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបំពេញបន្ថែមលើសេចក្តីណែនាំ*

*បច្ចេកទេសស្តីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់»។*

- ✓ ការជ្រើសរើសគម្រោងអាទិភាពចេញពីបញ្ជីគម្រោងវិនិយោគបឋម ត្រូវផ្តោតជាសំខាន់លើទិដ្ឋភាពបច្ចេកទេសនៃការកសាងគម្រោង, តម្លៃ, សេដ្ឋកិច្ច, ហិរញ្ញវត្ថុ, ច្បាប់, ហានិភ័យ, ផលប៉ះពាល់សង្គម បរិស្ថាន និងការប្រែប្រួលអាកាសធាតុ, យន្តការគ្រប់គ្រង និងអនុវត្តគម្រោង ។ គម្រោងអាទិភាពត្រូវដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត រួចបញ្ជូនទៅរដ្ឋបាលរាជធានី ខេត្ត ដើម្បីធ្វើសមាហរណកម្មទៅក្នុងផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត។
- ✓ គម្រោងវិនិយោគរបស់រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ត្រូវដាក់ប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់រដ្ឋបាលរាជធានី ខេត្ត ដើម្បីធ្វើការសម្របសម្រួល និងផ្តល់យោបល់ មុននឹងដាក់ជូនក្រុមប្រឹក្សារាជធានី ខេត្ត ត្រួតពិនិត្យ និងផ្តល់អនុលោមភាព។ បន្ទាប់មកសំណើគម្រោងអាទិភាពរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ នឹងត្រូវដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ទៅតាមអាទិភាពនៅថ្នាក់មូលដ្ឋាន ដែលជាតម្រូវការ និងសំណូមពររបស់រដ្ឋបាលនីមួយៗ តាមអភិក្រមពីក្រោមឡើងលើ ដោយផ្អែកតាម*«គោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត»* ដែលបានដាក់ឱ្យអនុវត្តតាមប្រកាសលេខ ៤៥៧ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ✓ ការធ្វើថវិកានីយកម្មគម្រោង គឺជាដំណាក់កាលដែលរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ធ្វើការកំណត់ប្រភពហិរញ្ញប្បទាន ដើម្បីរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ដោយផ្អែកលើផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ដែលបានរៀបចំរួច។ ដូចនេះ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់រវាងផែនការវិនិយោគសាធារណៈជាមួយនឹងថវិកានីយកម្មវិនិយោគសាធារណៈ ចាំបាច់ត្រូវរៀបចំឱ្យបានល្អ និងទាន់ពេលវេលានូវផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត។

*<u>ទិសដៅឆ្នាំ២០២៥ គឺការចរចាថវិការដ្ឋបាលរាជធានី ខេត្ត ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងត្រូវធ្វើការពង្រឹង និងតម្រង់ទិសផ្តោតលើគោលនយោបាយ និងវិស័យជាអាទិភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងមូល។ ដូចនេះ ក្នុងអំឡុងពេលចរចាថវិកា, រដ្ឋបាលរាជធានី ខេត្ត ត្រូវភ្ជាប់មកជាមួយនូវផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ឬយ៉ាងហោចណាស់បញ្ជីគម្រោងវិនិយោគចុងក្រោយរបស់រដ្ឋបាលរាជធានី ខេត្តសាមី ដែលបានឬកសុបរួច ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យផ្ទៀងផ្ទាត់ជាមួយ បញ្ជីគម្រោងវិនិយោគដែលបានដាក់បញ្ចូលនៅក្នុងគម្រោងថវិកាប្រចាំឆ្នាំ។</u>*

**ឃ.ការផ្ទេរ (ចំណាយអន្តរាគមន៍ និងឧបត្ថម្ភធន)**

ចំណាយអន្តរាគមន៍ (ជំពូក៦២÷អត្ថប្រយោជន៍សង្គម) និងចំណាយឧបត្ថម្ភធន (ជំពូក៦៥÷ឧបត្ថម្ភធន) ត្រូវរៀបចំលម្អិតឱ្យច្បាស់លាស់តាមគោលដៅ ដែលត្រូវសម្រេចដោយផ្អែកលើលក្ខណៈសម្បត្តិនៃអ្នកដែលទទួលផល និងចំនួនទឹកប្រាក់ដែលត្រូវពិនិត្យផ្តល់ជូន (គម្រោងចំណាយនេះត្រូវសរុបតារាងទី៤ និងទី៥) ដូចជា ឧបត្ថម្ភអត្ថប្រយោជន៍សន្តិសុខសង្គម ឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈ

សង្គម វប្បធម៌ និងឧបត្ថម្ភធនជូនថ្នាក់រដ្ឋបាលនីមួយៗ។ សម្រាប់ចំណាយគណៈបញ្ជាការឯកភាព ត្រូវគ្រោងក្នុងអនុគណនី៦២៩៨១ (អត្ថប្រយោជន៍សង្គមផ្សេងទៀត)។

រដ្ឋបាលរាជធានី ខេត្ត ត្រូវគ្រោងចំណាយឧបត្ថម្ភសមាជិកភាពជូនសមាគមក្រុមប្រឹក្សារាជធានី ខេត្ត ក្នុងអនុគណនី៦២០៤១ (ឧបត្ថម្ភដល់អង្គការមូលដ្ឋាន និងគាំទ្រកម្មវិធីផ្សេងៗ)។ រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ត្រូវគ្រោងចំណាយឧបត្ថម្ភសមាជិកភាពជូនសមាគមក្រុមប្រឹក្សាក្រុង ស្រុក និងឃុំ សង្កាត់ ចំនួន២ភាគរយ (ពីរភាគរយ) នៃថវិកាផ្នែករដ្ឋបាលដកបន្ទុកបុគ្គលិក (ជំពូក៦៤) ដោយមិនរាប់បញ្ចូលនូវមន្ត្រីជាប់កិច្ចសន្យា (ប្រើប្រាស់តួលេខវិភាជមូលនិធិក្រុង ស្រុក និងឃុំ សង្កាត់ ជាមូលដ្ឋានក្នុងការគណនា) និងត្រូវគ្រោងក្នុងអនុគណនី៦២០៤១ (ឧបត្ថម្ភដល់អង្គការមូលដ្ឋាន និងគាំទ្រកម្មវិធីផ្សេងៗ)។

រដ្ឋបាលរាជធានី ខេត្ត គ្រោងថវិកា និងផែនការសកម្មភាពសេវាសង្គមដើម្បីគាំទ្រ ដូចជា÷ ជនមានពិការភាព, ជនងាយរងគ្រោះ និងសកម្មភាពគាំទ្រសេវាសង្គមផ្សេងៗដទៃទៀត ស្របតាម រចនាសម្ព័ន្ធថវិកាកម្មវិធីរបស់រដ្ឋបាលសាមី។

ផ្អែកតាមតារាងវិភាជន៍មូលនិធិក្រុង ស្រុក និងឃុំ សង្កាត់ ឆ្នាំ ២០២៥, រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ត្រូវគ្រោងចំណាយថវិកាសម្រាប់អនុវត្តសកម្មភាព និងគម្រោងអភិវឌ្ឍដែលគាំទ្រសកម្មភាពសេវាសង្គម និងអនាម័យបរិស្ថាន។ *<u>មុខសញ្ញាចំណាយសម្រាប់សេវាសង្គម និងអនាម័យបរិស្ថាន សម្រាប់រដ្ឋបាលក្រុង ស្រុក និង រដ្ឋបាលឃុំ សង្កាត់ ត្រូវកំណត់ដោយសេចក្តីណែនាំរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ។</u>*

រដ្ឋបាលរាជធានី ខេត្ត ត្រូវជួបប្រជុំពិភាក្សាជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ដើម្បីរៀបចំផែនការសកម្មភាពការងារ និងគ្រោងថវិកា តាមមុខសញ្ញាចំណាយមានជាអាទិ៍ កិច្ចប្រជុំផ្សព្វផ្សាយ, បណ្តុះបណ្តាល និងប្រាក់បេសកកម្ម ដូចខាងក្រោម÷

- រដ្ឋបាលរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង ត្រូវគ្រោងថវិកាចំនួន ៨០លានរៀល
- រដ្ឋបាលខេត្តកណ្តាល ខេត្តតាកែវ ខេត្តព្រៃវែង ខេត្តពោធិ៍សាត់ ខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តកំពង់ឆ្នាំង ខេត្តប៉ៃលិន និងខេត្តកំពង់ធំ ត្រូវគ្រោងថវិកាចំនួន ៦០លានរៀល
- រដ្ឋបាលខេត្តក្រចេះ ខេត្តមណ្ឌលគិរី ខេត្តព្រះវិហារ ខេត្តកោះកុង ខេត្តស្វាយរៀង ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តកែប ខេត្តឧត្តរមានជ័យ និងខេត្តកំពត ត្រូវគ្រោងថវិកាចំនួន ៤០លានរៀល។

### ខ.ចំណាយផ្សេងៗ

ចំណាយជំពូក៦៣ (ពន្ធ និងអាករ) គឺសម្រាប់កាតព្វកិច្ចពន្ធដូចជាចំណាយលើអាករ លតាប័ត្រលើរថយន្ត ម៉ូតូរបស់រដ្ឋ ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងចំណាយបង់ពន្ធអាករផ្សេងៗទៀតតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន (គម្រោងចំណាយនេះត្រូវសរុបតារាងទី៦)។

ចំណាយជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) ត្រូវគ្រោងបម្រុងសម្រាប់ចំណាយចៃដន្យដែលអាចកើតមានជាយថាហេតុនៅក្នុងឆ្នាំអនុវត្ត។ សម្រាប់ឆ្នាំថវិកា២០២៥ ប្រភេទឥណទាននេះ គឺអនុញ្ញាតឱ្យគ្រោងក្នុងរង្វង់ ៥% នៃគម្រោងចំណាយសរុបរបស់រដ្ឋបាលនីមួយៗហើយខ្ទង់ចំណាយនេះពេលអនុវត្តត្រូវស្នើសុំនិយ័តភាពទៅបំពេញឱ្យជំពូកដទៃទៀត ដែលតម្រូវការចំណាយចៃដន្យកើតមានឡើងជាយថាហេតុ តម្រូវការចំណាយសម្រាប់អភិវឌ្ឍ ចំណាយសងបំណុលរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

## ៥. ការរៀបចំគម្រោងថវិកាផ្ទេរមុខងារ

### ៥.១ វិស័យសុខាភិបាល

រដ្ឋបាលរាជធានី ខេត្ត ដោយមានមន្ទីរសុខាភិបាលជាសេនាធិការត្រូវរៀបចំគម្រោងថវិកាស្របតាមប្រកាសអន្តរក្រសួងលេខ ១៨២ សហវ.ប្រក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពី *«លក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុ សម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលរាជធានី ខេត្ត សម្រាប់ការអនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាល»*។

### ៥.២ វិស័យអប់រំ

អនុលោមតាមអនុក្រឹត្យលេខ ២១៣ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងប្រកាសអន្តរក្រសួងលេខ ៣៨៥ សហវ.ប្រក.អថ ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៤ ស្តីពីលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុសម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានការិយាល័យអប់រំ យុវជន និងកីឡា ជាសេនាធិការ ត្រូវរៀបចំគម្រោងថវិកាសម្រាប់អនុវត្តមុខងារទាំង៣ ព្រមទាំងកញ្ចប់ថវិកាសម្រាប់ចំណាយបន្ទុកបុគ្គលិក និងចំណាយប្រតិបត្តិការរដ្ឋបាលរបស់ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ ជាឧបសម្ព័ន្ធនៃកញ្ចប់ថវិការដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់ពិភាក្សាភ្ជាប់គ្នាជាមួយគម្រោងថវិការបស់មន្ទីរអប់រំ យុវជន និងកីឡា និងរដ្ឋបាលកណ្តាលនៃក្រសួងអប់រំយុវជន និងកីឡា។

រដ្ឋបាលឃុំ សង្កាត់ ត្រូវគ្រោងថវិកាសម្រាប់ការងារការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ដែលស្ថិតនៅក្រោមការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់សាមី ស្របតាមអនុក្រឹត្យលេខ ២៤៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍។

### ៥.៣ ការអនុវត្តមុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ

រដ្ឋបាលរាជធានី ខេត្ត ដែលទទួលបានមុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ ត្រូវគ្រោងឥណទានចំណាយនៅក្នុងកញ្ចប់ថវិការដ្ឋបាលរាជធានី ខេត្តសាមី តាមចំណាត់ថ្នាក់មាតិកាថវិកា ដើម្បីទ្រទ្រង់ចំណាយបន្ទុកបុគ្គលិក ចំណាយប្រតិបត្តិការ និងរដ្ឋបាលនៅក្នុងមណ្ឌល។

**៥.៤ ការអនុវត្តមុខងារគ្រប់គ្រងមជ្ឈមណ្ឌល ព្យាបាល និងស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀន បណ្តោះអាសន្ន**

រដ្ឋបាលរាជធានី ខេត្ត គោលដៅដែលមានមជ្ឈមណ្ឌល ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនបណ្តោះអាសន្ន ត្រូវគ្រោងគោលរបបជូនជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនស្របតាមអនុក្រឹត្យលេខ ៩០ អនក្រ.បក ចុះថ្ងៃទី១៣ កក្កដា ឆ្នាំ ២០១៥ *"ស្តីពីការកែសម្រួលមាត្រា៧ នៃអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ"* ក្នុងកញ្ចប់ថវិការដ្ឋបាលរាជធានី ខេត្ត រៀងៗខ្លួន ដែលត្រូវគ្រោងក្នុងអនុគណនី ៦២០៣៦ (ឧបត្ថម្ភមណ្ឌលស្តារលទ្ធភាពពលកម្ម នីតិសម្បទា និងបណ្តុះបណ្តាលអភិវឌ្ឍន៍)។

**៥.៥ ការផ្ទេរមុខងារសេវាអនាម័យបរិស្ថាន**

សម្រាប់ការអនុវត្តមុខងារគ្រប់គ្រងសំណល់រឹង តាមទីប្រជុំជនក្រុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រដ្ឋបាលខេត្តត្រូវគ្រោងឥណទានក្នុងអនុគណនី៦៥០១២ ស្របតាមតារាងវិភាជន៍បែងចែក ដើម្បីឧបត្ថម្ភធនជូនរដ្ឋបាលក្រុង សម្រាប់ជាកញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន ក្នុងការអនុវត្តមុខងារ សេវាអនាម័យបរិស្ថាននៅរដ្ឋបាលក្រុងគោលដៅទាំង៣២។

រដ្ឋបាលក្រុងគោលដៅទាំង៣២ នឹងទទួលបានឥណទានថវិកា នៅក្នុងគណនី៦១០១ អនុគណនី ៦១០១១ (សេវាអនាម័យ) សម្រាប់ចំណាយអនុវត្តមុខងារសេវាអនាម័យបរិស្ថាន។

**៥.៦ ការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ**

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវគ្រោងចំណាយសម្រាប់អនុវត្តមុខងារ នៃការិយាល័យជំនាញទាំង១៩ វិស័យរបស់មន្ទីរជំនាញរាជធានី ខេត្ត ដែលបានធ្វើសមាហរណកម្មចូលទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្រោយពីបានទទួលតួលេខវិភាជន៍ពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**៦. ការរៀបចំផែនការលទ្ធកម្មសាធារណៈ**

ដើម្បីឱ្យការអនុវត្តគម្រោងអាទិភាពបានទាន់ពេលវេលា និងឆ្លើយតបបានតាមតម្រូវការចាំបាច់ជាពិសេស ដើម្បីធានាថារាល់គម្រោងអាទិភាពមានប្រភពធនធានថវិកាគ្រប់គ្រាន់សម្រាប់អនុវត្ត, រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ ដោយផ្អែកលើគម្រោងអាទិភាពដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត និងតួលេខកញ្ចប់ថវិកាប្រចាំឆ្នាំ។

សេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ដែលកន្លងមកត្រូវបានរៀបចំ និងអនុម័តក្រោយកិច្ចចរចាថវិកា ត្រូវជំនួសដោយធ្វើការពិនិត្យ និងសម្រេចផែនការលទ្ធកម្មនៅក្នុងក្របខ័ណ្ឌនៃការចរចាថវិកានៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដូចគ្នានេះដែរ, រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវដាក់សេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យ និងអនុម័ត ក្នុងពេលដំណាលគ្នានឹងគម្រោងថវិកាប្រចាំឆ្នាំ ដែលត្រូវដាក់ជូនអភិបាលរាជធានី ខេត្ត ដើម្បីផ្តល់អនុលោមភាព។

សេចក្តីព្រាងផែនការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវធ្វើការកែសម្រួលឡើងវិញ ដោយផ្អែកលើលទ្ធផលនៃការចរចាថវិកា រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងអនុម័តឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា។

### ៧. ការរៀបចំផែនការឥណទានវិនិយោគរដ្ឋទេយ្យបុរេប្រទាន

រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំផែនការឥណទានរដ្ឋទេយ្យបុរេប្រទាន ដំណាលគ្នានឹងការរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំសម្រាប់ពិនិត្យ និងពិភាក្សាក្នុងកិច្ចប្រជុំចរចាគម្រោងថវិកាប្រចាំឆ្នាំ។ ដូចគ្នានេះដែរ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវភ្ជាប់សេចក្តីព្រាងផែនការឥណទានរដ្ឋទេយ្យបុរេប្រទានមកជាមួយនឹងគម្រោងថវិកាឆ្នាំ ២០២៥ ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវធានាថាឥណទានថវិកាដែលត្រូវយកមករៀបចំតារាង ដូចតារាងភ្ជាប់ឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន មិនត្រូវត្រួតគ្នានឹងឥណទានថវិកាដែលត្រូវបានគ្រោងទុកអនុវត្តកិច្ចលទ្ធកម្មសាធារណៈ តាមនីតិវិធីទូទាត់ត្រង់ និងនីតិវិធីចំណាយផ្សេងទៀតទេ។

### ៨. ការរៀបចំផែនការឥណទានតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវរៀបចំផែនការឥណទាន សម្រាប់ចំណាយការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំ ស្របតាមខ្លឹមសារនៃប្រកាសលេខ ៥៥៨ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ ២០២២ ស្តីពីវិធាន និងនីតិវិធីចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងផែនការឥណទានសម្រាប់ចំណាយប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេស ស្របតាមខ្លឹមសារនៃប្រកាសលេខ ៥៥៩ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ ២០២២ ស្តីពីវិធាន និងនីតិវិធីចំណាយប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### ៩. វិធីសាស្ត្រនៃការរៀបចំគម្រោងចំណូលចំណាយថវិកា

គម្រោងចំណូលចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំដោយមានការទទួលខុសត្រូវរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ហើយត្រូវពិនិត្យ និងអនុម័តដោយក្រុមប្រឹក្សានៃថ្នាក់រដ្ឋបាលនីមួយៗ។

ដើម្បីឱ្យការរៀបចំគម្រោងចំណូល-ចំណាយថវិកា អាចប្រព្រឹត្តទៅដោយរលូន និងគ្រប់ជ្រុងជ្រោយជាពិសេស ឈានទៅសម្រេចគោលដៅនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ការរៀបចំត្រូវផ្អែកលើមូលដ្ឋានព័ត៌មានលទ្ធផលនៃការអនុវត្តឆ្នាំមុន បែបបទ និងនីតិវិធីដែលបានកំណត់ និងគោលការណ៍ចំណាយចាំបាច់។ រដ្ឋបាលថ្នាក់ក្រោមជាតិអាចអញ្ជើញប្រធានមន្ទីរ/អង្គភាពពាក់ព័ន្ធចូលរួមដើម្បីទទួលបានព័ត៌មាន និងធាតុចូលគ្រប់ជ្រុងជ្រោយ។

## ៩.១. ការរៀបចំគម្រោងចំណូល

❖ **រដ្ឋបាលរាជធានី ខេត្ត**

អភិបាលនៃគណៈអភិបាលរាជធានី ខេត្តត្រូវអញ្ជើញប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានសាខាពន្ធដារ ប្រធានមន្ទីរជំនាញ និងអង្គភាពដែលមានការពាក់ព័ន្ធក្នុងការប្រមូលចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ មកពិភាក្សាគិតគូររៀបចំដើម្បីកំណត់ឱ្យបាននូវគម្រោងសរុបចំណូលថវិកាប្រចាំឆ្នាំ ២០២៥។

ក្នុងការរៀបចំគម្រោងចំណូលរបស់រដ្ឋបាលរាជធានី ត្រូវមានការចូលរួមពីអភិបាលនៃគណៈអភិបាលខណ្ឌ ដើម្បីពិភាក្សាផ្តល់ព័ត៌មានពីលទ្ធភាពប្រមូលចំណូលមិនមែនសារពើពន្ធ (ចំណូលទទួលបានពីការផ្តល់សេវារដ្ឋបាលនៅមូលដ្ឋាន)។

❖ **រដ្ឋបាលក្រុង ស្រុក ខណ្ឌ**

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ដោយមានជំនួយពីប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ ត្រូវព្យាករណ៍នូវលទ្ធភាពប្រមូលចំណូលមិនមែនសារពើពន្ធនៅមូលដ្ឋាន បូករួមជាមួយចំណូលដែលទទួលបានពីការវិភាជមូលនិធិក្រុង ស្រុក ដើម្បីកំណត់នូវកញ្ចប់គម្រោងសរុបចំណូលថវិកាប្រចាំឆ្នាំ២០២៥ របស់រដ្ឋបាលក្រុង ស្រុកផ្ទាល់។ រដ្ឋបាលក្រុង ស្រុក ត្រូវអញ្ជើញប្រធានមន្ទីរ/អង្គភាពពាក់ព័ន្ធចូលរួមដើម្បីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ។

អភិបាលនៃគណៈអភិបាលខណ្ឌ ដោយមានជំនួយពីប្រធានការិយាល័យផែនការ និងហិរញ្ញវត្ថុ ត្រូវព្យាករណ៍លទ្ធភាពប្រមូលចំណូលមិនមែនសារពើពន្ធនៅមូលដ្ឋានប្រចាំឆ្នាំ ដើម្បីរាយការណ៍នៅពេលទៅចូលរួមប្រជុំរៀបចំគម្រោងចំណូលប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី។

❖ **រដ្ឋបាលឃុំ សង្កាត់**

មេឃុំ ចៅសង្កាត់ ត្រូវព្យាករណ៍អំពីលទ្ធភាពប្រមូលចំណូលមិនមែនសារពើពន្ធ (ចំណូលសេវារដ្ឋបាល) នៅមូលដ្ឋាន បូករួមជាមួយចំណូលដែលទទួលបានពីការវិភាជ មូលនិធិឃុំ សង្កាត់ និងចំណូលទទួលបានបន្ថែមលើមូលនិធិឃុំ សង្កាត់សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ដើម្បីកំណត់ឱ្យបាននូវកញ្ចប់គម្រោងសរុបចំណូលថវិកាប្រចាំឆ្នាំ។

## ៩.២. ការរៀបចំគម្រោងចំណាយ

❖ **រដ្ឋបាលរាជធានី ខេត្ត**

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវរៀបចំប្រជុំជាមួយក្រុមការងារថវិកា ដែលបានបង្កើតឡើងដូចដែលបានចែងក្នុងគោលការណ៍ណែនាំស្តីពី «*ការរៀបចំថវិកាកម្មវិធី*» ដើម្បីរៀបចំផែនការចំណាយរយៈពេល១ឆ្នាំរបស់រដ្ឋបាលសាមី ដោយផ្អែកលើផែនការយុទ្ធសាស្ត្រថវិកាដែលបានដាក់ចេញ។ ក្រុមការងារថវិកាសំខាន់ៗ រួមមាន នាយករដ្ឋបាល, នាយកទីចាត់ការហិរញ្ញវត្ថុ, នាយកទីចាត់ការវិនិយោគ, និងមន្ត្រីជំនាញពាក់ព័ន្ធ។ ដើម្បីឱ្យការរៀបចំ និងការអនុវត្តកម្មវិធី អាចប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព រដ្ឋបាលខេត្តត្រូវកំណត់ឱ្យមានអ្នកទទួលខុសត្រូវចំពោះកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព។

អភិបាលនៃគណៈអភិបាលរាជធានី ត្រូវរៀបចំប្រជុំដោយមានការចូលរួមមន្ត្រីជំនាញពាក់ព័ន្ធ ជាពិសេស មន្ត្រីទទួលបន្ទុករៀបចំគម្រោងចំណាយ ដើម្បីពិភាក្សាអំពីតម្រូវការចំណាយតាមអាទិភាព និងតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា។ គម្រោងចំណាយរបស់រដ្ឋបាលរាជធានី ត្រូវបូកបញ្ចូលនូវគម្រោងចំណាយរបស់រដ្ឋបាលខណ្ឌ ក្រោយពេលដែលរដ្ឋបាលខណ្ឌ បានផ្ញើជូននូវគម្រោងថវិកាដែលក្រុមប្រឹក្សារបស់ខ្លួនបានអនុម័តរួច។

ក្រុមការងារថវិកា ត្រូវបន្តរៀបចំថវិកាកម្មវិធីរបស់រដ្ឋបាលរាជធានី ខេត្ត ដូចដែលបានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃ*គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី សម្រាប់រដ្ឋបាលរាជធានី ខេត្ត ដែលត្រូវបានដាក់ឱ្យអនុវត្តដោយប្រកាសលេខ ៥១៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។*

រដ្ឋបាលរាជធានី ខេត្ត ដែលបានបុរេប្រទានកន្លងមកពុំទាន់បានទូទាត់ ត្រូវគ្រោងឥណទានចំណាយថវិកាលម្អិតតាមជំពូក គណនី និងអនុគណនី ស្របតាមខ្លឹមសារ ចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិកា តាមមុខសញ្ញាចំណាយដែលបានអនុវត្តដើម្បីទូទាត់ជិរៈបញ្ជីបុរេប្រទាន។

- **រដ្ឋបាលក្រុង ស្រុក ខណ្ឌ**

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំការប្រជុំដោយមានការចូលរួមពីនាយករដ្ឋបាល ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ និងមន្ត្រីជំនាញពាក់ព័ន្ធ ដើម្បីពិភាក្សាអំពីតម្រូវការ និងអាទិភាពចំណាយ តាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបានបុរេប្រទានកន្លងមកពុំទាន់បានទូទាត់ ត្រូវគ្រោងឥណទានចំណាយថវិកាលម្អិតតាមជំពូក គណនី និងអនុគណនី ស្របតាមខ្លឹមសារ ចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិកា និងមុខសញ្ញាចំណាយដែលបានអនុវត្ត។

- **រដ្ឋបាលឃុំ សង្កាត់**

មេឃុំ និងចៅសង្កាត់ត្រូវរៀបចំប្រជុំ ដោយមានការចូលរួមពីស្មៀន ជំនួយការហិរញ្ញវត្ថុ និងមន្ត្រីជំនាញពាក់ព័ន្ធ ដើម្បីពិភាក្សាអំពីតម្រូវការចំណាយទៅតាមលំដាប់លំដោយអាទិភាព តាមខ្លឹមសារចំណាត់ថ្នាក់នៃមាតិកាថវិកា។

មេឃុំ ចៅសង្កាត់ ត្រូវរៀបចំយន្តការការងារដោយត្រូវប្រគល់មុខងារភារកិច្ចទៅឱ្យជំនួយការហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់ ក្នុងការបំពេញតួនាទី និងភារកិច្ចឱ្យបានពេញលេញ ស្របតាមប្រការ១២ នៃប្រកាសអន្តរក្រសួងលេខ០០២ សហវ.ប្រក ចុះថ្ងៃទី៤ ខែមករា ឆ្នាំ ២០២២ ស្តីពីការជ្រើសរើស និងការកំណត់តួនាទី និងភារកិច្ចរបស់ជំនួយការហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់ បានកំណត់តួនាទី និងភារកិច្ច ជំនួយការហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់ ដូចខាងក្រោម÷

- ✓ ជារដ្ឋទេយ្យករបុរេប្រទាន
- ✓ ជារដ្ឋទេយ្យករចំណូល
- ✓ ជាភ្នាក់ងារបើកផ្តល់

✓ ជាជំនួយការឱ្យមេឃុំ ចៅសង្កាត់ក្នុងកិច្ចការ ដូចជា ការរៀបចំផែនការ និងគម្រោងថវិកាប្រចាំឆ្នាំ, ការគ្រប់គ្រង ពិនិត្យ និងតាមដានការអនុវត្តថវិកា, ការរៀបចំរបាយការណ៍ និងប្រព័ន្ធរបាយការណ៍ផ្ទៃក្នុង ដើម្បីពិនិត្យតាមដានការអនុវត្តថវិកា, ការរៀបចំរបាយការណ៍ស្ដីពីការអនុវត្តថវិកាតាមទម្រង់របាយការណ៍រួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ការអនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុដោយគោរពតាមវិធាន និងបទបញ្ញត្តិហិរញ្ញវត្ថុសាធារណៈជាធរមាន និងការបំពេញការងារពាក់ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុផ្សេងទៀតតាមការប្រគល់របស់មេឃុំ ចៅសង្កាត់។

## ១០. ការចរចាថវិកាផ្អែកតាមកម្មវិធីរបស់រដ្ឋបាលរាជធានី ខេត្ត

ការចរចាថវិការបស់រដ្ឋបាលរាជធានី ខេត្តនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបច្ចុប្បន្នផ្អែកលើធាតុចូល និងតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា នឹងត្រូវធ្វើការផ្លាស់ប្ដូរទៅរកការចរចាថវិកាតាមកម្មវិធីដោយផ្អែកលើលទ្ធផលក្នុងឆ្នាំនៃកម្មវិធី និងការពង្រឹង និងតម្រង់ទិសការចរចាថវិកាផ្ដោតលើគោលនយោបាយ និងវិស័យជាអាទិភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងមូល។

គោលបំណងសំខាន់នៃការចរចាថវិកាតាមកម្មវិធី គឺការកសាងការផ្សារភ្ជាប់ទំនាក់ទំនងឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀតរវាងគោលនយោបាយ, ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងការរៀបចំថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងរវាងអាទិភាពតាមវិស័យសម្រាប់ថវិកាមន្ទីរជំនាញរាជធានី ខេត្តទៅនឹងផែនការ/កម្មវិធីនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។

ចាប់ពីឆ្នាំ ២០២៤ តទៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងសាកល្បងការចរចាថវិកាតាមកម្មវិធីសម្រាប់គម្រោងថវិកាឆ្នាំ ២០២៥ ដោយជ្រើសរើសរដ្ឋបាលខេត្តចំនួន ៦ រួមមាន ខេត្តកំពង់ចាម, ខេត្តព្រះវិហារ, ខេត្តឧត្តរមានជ័យ ខេត្តប៉ៃលិន ខេត្តកោះកុង និងខេត្តត្បូងឃ្មុំ។

## ១១. កាលបរិច្ឆេទនៃការរៀបចំ និងការអនុម័តគម្រោងថវិកា

បន្ទាប់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជូនដំណឹងអំពីកញ្ចប់ថវិកាបឋមទៅរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលសាមី ដូចខាងក្រោម÷

❖ **រដ្ឋបាលរាជធានី ខេត្ត**

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រោយពីបានទទួលកញ្ចប់ថវិកាបឋមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវព្យាករណ៍នូវលទ្ធភាពចំណូលសរុបទាំងអស់ដើម្បីរៀបចំគម្រោងថវិកា និងដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័តយ៉ាងយូរបំផុតត្រឹមថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០២៤។

គម្រោងថវិការបស់រដ្ឋបាលរាជធានី ត្រូវបូកបញ្ចូលគម្រោងថវិការបស់រដ្ឋបាលខណ្ឌ ចំណុះរដ្ឋបាលរាជធានី។ អភិបាលនៃគណៈអភិបាលរាជធានី ត្រូវបែងចែក និងជូនដំណឹងអំពីកញ្ចប់ថវិកាដល់រដ្ឋបាលខណ្ឌយ៉ាងយូរបំផុតត្រឹមថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០២៤ និងត្រូវជួយគាំទ្រឱ្យរដ្ឋបាលខណ្ឌ រៀបចំគម្រោងថវិកាដើម្បីដាក់ឆ្លងក្រុមប្រឹក្សារបស់ខ្លួនឱ្យបានយ៉ាងយូរ ត្រឹមថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០២៤។

រដ្ឋបាលរាជធានី ខេត្ត ត្រូវផ្ញើគម្រោងថវិកា ដែលក្រុមប្រឹក្សារាជធានី ខេត្តបានអនុម័តរួចទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យ៉ាងយូរបំផុតត្រឹមថ្ងៃទី១ ខែកក្កដា ឆ្នាំ ២០២៤។

❖ **រដ្ឋបាលក្រុង ស្រុក ខណ្ឌ**

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ក្រោយពីបានទទួលចំណូលពីការវិភាជមូលនិធិក្រុង ស្រុក ចំណូលចែករំលែក និងលទ្ធភាពចំណូលដែលអាចប្រមូលបាននៅមូលដ្ឋាន ត្រូវចាប់ផ្តើមរៀបចំគម្រោងថវិកា និងដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនពិនិត្យ និងអនុម័តយ៉ាងយូរបំផុតត្រឹមថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០២៤។

រដ្ឋបាលក្រុង ស្រុក ត្រូវផ្ញើគម្រោងថវិកា ដែលក្រុមប្រឹក្សាក្រុង ស្រុក បានអនុម័តទៅរដ្ឋបាលខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយូរបំផុតត្រឹមថ្ងៃទី១ ខែកក្កដា ឆ្នាំ ២០២៤។

អភិបាលនៃគណៈអភិបាលខណ្ឌ ក្រោយពីបានទទួលកញ្ចប់ថវិកា (សរុបចំណូល) ពីរដ្ឋបាលរាជធានី ត្រូវដំណើរការរៀបចំគម្រោងថវិកា និងដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនពិនិត្យ និងអនុម័ត យ៉ាងយូរបំផុតត្រឹមថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០២៤ ហើយផ្ញើទៅរដ្ឋបាលរាជធានីយ៉ាងយូរបំផុតត្រឹមថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០២៤។

មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ត្រូវរៀបចំកម្មវិធីដោយសម្របសម្រួលជាមួយអភិបាលនៃគណៈអភិបាលខេត្ត ដើម្បីពិនិត្យ និងបញ្ជាក់អនុលោមភាពលើគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុក ដោយមានការចូលរួមពីមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយូរបំផុតត្រឹមថ្ងៃទី០១ ខែសីហា ឆ្នាំ ២០២៤។

❖ **រដ្ឋបាលឃុំ សង្កាត់**

មេឃុំ ចៅសង្កាត់នីមួយៗ ក្រោយពីទទួលបានចំណូលពីការវិភាជមូលនិធិឃុំ សង្កាត់ *ចំណូលចែករំលែក* និងលទ្ធភាពចំណូល ដែលអាចប្រមូលបាននៅនឹងមូលដ្ឋានត្រូវដំណើរការរៀបចំគម្រោងថវិកា និងដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនពិនិត្យ និងអនុម័តយ៉ាងយូរបំផុតត្រឹមថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០២៤។

រដ្ឋបាលឃុំ សង្កាត់ ត្រូវផ្ញើជូនគម្រោងថវិកាដែលក្រុមប្រឹក្សាឃុំ សង្កាត់បានអនុម័តរួច ទៅរដ្ឋបាលរាជធានី ខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយូរបំផុតត្រឹមថ្ងៃទី០១ ខែកក្កដា ឆ្នាំ ២០២៤។

❖ **មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត**

មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវធ្វើការបូកសរុបថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រចាំរាជធានី ខេត្តនីមួយៗតាមគំរូតារាងឧបសម្ព័ន្ធទី១ "ក" និង ១ "ខ" (តារាងសរុបចំណូលថវិការបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់) និងគំរូតារាងឧបសម្ព័ន្ធទី២ "ក" និង ២ "ខ" (តារាងសរុបចំណាយថវិការបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់) និងផ្ញើជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយូរបំផុតត្រឹមថ្ងៃទី៥ ខែកក្កដា ឆ្នាំ ២០២៤។

រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំរចនាសម្ព័ន្ធថវិកាកម្មវិធី និងគម្រោងចំណូល ចំណាយថវិកាឆ្នាំ ២០២៥ ទៅតាមទម្រង់ដូចក្នុងគំរូតារាងឧបសម្ព័ន្ធទី៣។

រដ្ឋបាលរាជធានី ខេត្តត្រូវរៀបចំតារាងបូកសរុបចំណូលកម្រៃសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងចំណូលកម្រៃសេវា និងចំណូលពីការពិន័យជាប្រាក់ដែលប្រមូលនៅមន្ទីរអង្គភាពជំនាញរាជធានី ខេត្ត ដូចមានក្នុងតារាងឧបសម្ព័ន្ធទី៣ "ក"។

## ១២. សេចក្តីសន្និដ្ឋាន

សារាចរណែនាំនេះ បានកំណត់ក្របខ័ណ្ឌ និងវិធានការ ព្រមទាំងគោលការណ៍ និងបច្ចេកទេសក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគ្រោងចំណូល និងចំណាយសម្រាប់ជាមូលដ្ឋានដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដើម្បីរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួន សំដៅធ្វើយ៉ាងណាឱ្យការប្រើប្រាស់ថវិកាឆ្លើយតបបានដោយមានប្រសិទ្ធភាពទៅនឹងការសម្រេចបានគោលបំណង គោលនយោបាយ កម្មវិធី និងវិស័យអាទិភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

ទោះជាយ៉ាងណាក្តី ដើម្បីឱ្យគោលដៅទាំងឡាយ ដែលបានដាក់ចេញក្នុងសារាចរណែនាំនេះ អាចអនុវត្តសម្រេចបានជោគជ័យ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវខិតខំថែមទៀតប្រកបដោយឆន្ទៈប្តូរផ្តាច់ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកា ដោយខិតខំគោរពឱ្យបានខ្ជាប់ខ្ជួនតាមក្របខ័ណ្ឌ និងបណ្តាវិធានការ ព្រមទាំងគោលការណ៍ និងបច្ចេកទេសទាំងឡាយ ទាំងផ្នែកចំណូល និងផ្នែកចំណាយដែលកំណត់ដោយសារាចរណែនាំនេះ។ ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលរួមមាន អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ និងអង្គភាពពាក់ព័ន្ធ នឹងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសជាប្រចាំដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ឆ្នាំ ២០២៥-២០២៧ និងគម្រោងថវិកាឆ្នាំ ២០២៥ ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រេចបានជោគជ័យ។

ទទួលបានសារាចរណែនាំនេះ គ្រប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវរៀបចំជាប្រញាប់នូវផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ ២០២៥-២០២៧ (លើកលែងរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់) និងគម្រោងចំណូល-ចំណាយថវិការបស់ខ្លួនសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥ ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ ឱ្យបានទាន់ពេលវេលាតាមកាលបរិច្ឆេទខាងលើកុំបីអាក់ខាន។ ក្នុងការអនុវត្តសារាចរណែនាំនេះ ប្រសិនបើរដ្ឋបាលថ្នាក់ក្រោមជាតិ មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់មកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ឬក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ)។

ថ្ងៃពុធ ១២កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- មន្ទីរជំនាញរាជធានី ខេត្ត
- រតនាគាររាជធានី ខេត្ត
- រដ្ឋបាលរាជធានី ខេត្ត
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- រដ្ឋបាលឃុំ សង្កាត់
  "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ